# សេចក្ដីជូនដំណឹង

## អបអរទិវានៃក្ដីស្រឡាញ់ និងកិច្ចសន្ទនាអំពីការបន្តគាំទ្រ និងលើកកម្ពស់ក្ដីស្រឡាញ់ចម្រុះរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាក្រោមមូលបទ «សាមគ្គីដើម្បីក្ដីស្រឡាញ់»

រាជធានីភ្នំពេញ៖ អង្គការសហគមន៍ឥន្ទធនូកម្ពុជា ក្រុមអ្នកស្ម័គ្រចិត្ត និងបណ្ដាញអង្គការសង្គមស៊ីវិល[1]ធ្វើការលើសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា សិទ្ធិនិន្នាភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ សិទ្ធិសុខភាពផ្លូវភេទ និងសិទ្ធសុខភាពបន្តពូជ នៅប្រទេសកម្ពុជា អបអរទិវានៃសេចក្ដីស្រឡាញ់តាមរយៈ **កិច្ចសន្ទនាអំពីការបន្តគាំទ្រ និងលើកកម្ពស់ក្ដីស្រឡាញ់ចម្រុះរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា** និងការសម្ដែងសិល្បៈដោយរបស់សិល្បករ-ការិនីខ្មែរអាជីព មានទេពកោសល្យ និងល្បីល្បាញ ដែលនឹងប្រព្រឹត្តទៅនៅ **ថ្ងៃព្រហស្បតិ៍ ទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥ ចាប់ពីម៉ោង ០២៖០០រសៀល ដល់ម៉ោង ៥៖៣០ល្ងាច នៅសណ្ឋាគារកាំប៉ូឌីយ៉ាណា** (Cambodiana Hotel) ក្នុងគោលបំណង៖

- ចែករំលែក និងរៀនសូត្រអំពីរឿងរ៉ាវ បទពិសោធន៍ ក៏ដូចជាស្ថានភាពរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ក្នុងភាពជាគូស្រករ និងភាពជាគ្រួសារ។
- ចែករំលែក និងរៀនសូត្របទពិសោធរបស់ឪពុកម្ដាយ អាណាព្យាបាល និងញាតិមិត្តរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា អំពីការទទួលស្គាល់ ទទួលយក និងការគាំទ្រកូនចៅ សាច់ញាតិ និងមិត្តភក្ដិដែលជាអ្នកស្រឡាញ់ភេទដូចគ្នា។
- បង្ហាញពីការរួមចំណែករបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកគាំទ្រ រួមទាំងវិស័យសិល្បៈ និងសារព័ត៌មានក្នុងការបន្តផ្សព្វផ្សាយការយល់ដឹងអំពីស្ថានភាព សក្ដានុពល និងតម្រូវការអាទិភាពរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងសង្គមខ្មែរ។
- បង្កឱកាសដល់សមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាបានបន្តជួបសន្ទនាជាមួយអ្នកគាំទ្ររួមមានតំណាងក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល ឪពុកម្ដាយ ឬ អាណាព្យាបាល អ្នកសារព័ត៌មាន និងអ្នកពាក់ព័ន្ធ ដើម្បីបង្ហាញការបន្តគាំទ្រ និងលើកកម្ពស់ភាពចម្រុះនៃសេចក្ដីស្រឡាញ់ រាប់ទាំងក្ដីស្រឡាញ់របស់គូស្រករភេទដូចគ្នា ភេទផ្ទុយគ្នា ក្ដីស្រឡាញ់ចំពោះឪពុកម្ដាយ បងប្អូន មិត្តភក្ដិ សហគមន៍ ក្ដីស្រឡាញ់ចំពោះសង្គមជាតិ និងមនុស្សជាតិលើពិភពលោកប្រកបដោយព្រហ្មវិហារធម៌។
- បង្ហាញពីការរួមចំណែកជំរុញឱ្យមានវឌ្ឍនភាពបន្តទៀតក្នុងការការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេសសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា ស្របតាមការប្ដេជ្ញាចិត្តរបស់ភាគីពាក់ព័ន្ធ ជាពិសេសរាជរដ្ឋាភិបាលកម្ពុជា បណ្ដាញអង្គការសង្គមស៊ីវិល សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ភ្នាក់ងារអង្គការសហប្រជាជាតិ និងស្ថានទូតប្រចាំប្រទេសកម្ពុជាមួយចំនួន ក្នុងការចូលរួមអនុវត្តអនុសាសន៍យន្តការការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ (យូ.ភី.អ) ជុំទី៤ ទៅលើសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា ដែលកម្ពុជាបានទទួលយក។

សូមជម្រាបផងដែរថា កិច្ចសន្ទនាអំពីការបន្តការគាំទ្រ និងលើកកម្ពស់ក្ដីស្រឡាញ់ចម្រុះរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា នេះនឹងប្រព្រឹត្តិទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្ដម កែវ រ៉េមី ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា** ដែលតែងតែបង្ហាញជានិច្ចនូវឆន្ទៈបន្តការយកចិត្តទុកដាក់ គាំទ្រ និងលើកកម្ពស់ក្ដីស្រឡាញ់ចម្រុះរបស់

---

[1] ១. អង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) ២.ក្រុមស្ម័គ្រចិត្តយុវជនអ្នកស្រឡាញ់ភេទដូចគ្នា ក្ដីស្រឡាញ់គឺចម្រុះ ៣. អង្គការជីវិតស្រស់បំព្រង ៤. មូលនិធីមីក្រូឥន្ទធនូអន្តរជាតិ ៥.អង្គការក្លាហាន ៦. អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (រ៉ាក់) ៧. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ៨. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា ៩. អង្គការនារីដើម្បីសន្តិភាព ១០. អង្គការសីលការកម្ពុជា។

សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។ កម្មវិធីនេះនឹងមានការអញ្ជើញចូលរួមរបស់សមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាមកពី ២០ ខេត្ត-រាជធានី សិល្បៈករ-ការនី ឪពុកម្តាយ សមាជិកក្រុមគ្រួសារ តំណាងក្រសួងពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន តំណាងស្ថានទូត ភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា បណ្តាញអង្គការសង្គមស៊ីវិល វិស័យឯកជន ព្រមទាំងអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ចំនួនប្រមាណ **២៧០រូប**។

សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាបានលើកឡើងថា៖ *«អត្ថន័យ និងគុណតម្លៃនៃសេចក្តីស្រឡាញ់គឺជ្រាលជ្រៅ និងធំធេងណាស់នៅក្នុងសង្គមខ្មែរ រាប់ទាំងក្តីស្រឡាញ់នៃជីវិតគូស្រករ និងគ្រួសារ ដែលជា* ***សេចក្តីស្រឡាញ់ដ៏ស្មោះស្ម័គ្រចេញពីបេះដូង ការយល់ចិត្តគ្នា យកចិត្តទុកដាក់ និងអធ្យាស្រ័យគ្នា ពោរពេញដោយភាពផ្អែមល្ហែម កក់ក្តៅ និងសុភមង្គល ប្រៀបបាននឹងផ្ទះដែលមានគ្រឹះដ៏រឹងមាំ*** *។ ក្នុងនាមជាពលរដ្ឋខ្មែរ និងជាសមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា យើងប្តេជ្ញាចិត្តចូលរួមថែរក្សានូវគុណតម្លៃរួមដ៏ល្អផូរផង់នេះ ហើយសង្ឃឹមថានៅពេលដ៏ឆាប់ខាងមុខ ស្នាមមេដៃបញ្ជាក់ពីសក្ខីភាពនៃសេចក្តីស្រឡាញ់របស់យើងនឹងត្រូវបានផ្តិតលើសំបុត្រអាពាហ៍ពិពាហ៍ស្របតាមច្បាប់តែមួយ ស្មើភាពគ្នាក្នុងភាពជាសហព័ទ្ធ និងគ្រួសារ ក្រោមការដឹកនាំប្រកបដោយការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលនៃយើង ដើម្បីបង្ហាញនូវទំនុកចិត្ត និងការពារសិទ្ធិ ក៏ដូចជាអត្ថប្រយោជន៍ជាច្រើនដែលធានាដោយច្បាប់ បន្ថែមពីការប្រគល់បេះដូងឱ្យគ្នា និងពិធីមង្គលតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ។ សំបុត្រអាពាហ៍ពិពាហ៍ពិតជាមានតម្លៃខ្លាំងណាស់ ដោយបង្ហាញនូវការគោរព និងទំនុកចិត្តចំពោះគ្នាក្នុងភាពជាគូស្រករដែលយើងប្តេជ្ញាចិត្តចាប់ដៃ ហើយរស់នៅជាមួយគ្នាដល់សក់ស្កូវ និងចាស់ព្រឹទ្ធចាស់ព្រេង ហើយជូនចំពោះអ្នកមានគុណជាទីគោរពស្រឡាញ់របស់យើងបានចិញ្ចឹមបីបាច់ថែរក្សា ហើយការពារយើងជារៀងដរាប នៅខណៈពេលទទួលនូវពរជ័យ សិរីមង្គល ជាសាក្សីនៃថ្ងៃដ៏មានអត្ថន័យបំផុតមួយក្នុងជីវិត។»*

***«យើងទាំងពីរនាក់ស្រឡាញ់ ចាប់ដៃ និងរួមរស់កសាងជាគ្រួសារជាមួយគ្នាអស់រយៈពេលជាង២០ឆ្នាំហើយ យើងក៏មានកូនចំនួន២នាក់ផងដែរ។ គ្រួសាររបស់យើងរស់នៅជាមួយគ្នាយ៉ាងសុខដុម ខិតខំរកស៊ីដើម្បីអនាគតល្អ ចែករំលែកទុក្ខធុរៈ មើលថែគ្នា និងកូនៗ ហើយផ្តត់ផ្គង់ឱ្យពួកគេរៀនសូត្រ។ សម្រាប់ពួកយើង គ្រួសារមានអត្ថន័យធំធេងណាស់ ហើយទឹកចិត្តយើងជាឪពុកម្តាយគឺលះបង់គ្រប់យ៉ាងដើម្បីឲ្យកូនមានអនាគតល្អ។ ពួកយើងស្រឡាញ់កូនៗអស់ពីបេះដូង និងស្មើនឹងកែវភ្នែករបស់យើង។ ពួកយើងស្រមៃចង់បានគ្រួសារមួយដែលមានការទទួលយក និងទទួលស្គាល់ពេញលេញ មានច្បាប់អាពាហ៍ពិពាហ៍ដើម្បីការពារពួកយើង និងកូនៗ ជាពិសេសយើងចង់មានឈ្មោះជាឪពុកម្តាយនៅក្នុងសំបុត្រកំណើតកូន ហើយមានសៀវភៅគ្រួសារមួយដែលបញ្ជាក់ពីគ្រួសាររបស់យើងដូចគេដូចឯង។»*** ~ ប៊ុន គីម និងសុភ័ក្រ្ក គូស្រករភេទដូចគ្នារស់នៅខេត្តកំពត។

***«ជាឪពុកម្តាយរបស់គេ យើងបង្កើតកូនបានតែរូបរាងនោះទេ តែចិត្តគំនិតរបស់គេ គេចូលចិត្តអ្វី ស្រឡាញ់អ្វី គឺជាជីវិត និងការសម្រេចចិត្តរបស់គេ។ យើងមិនអាចចិញ្ចឹមគេពេញមួយជីវិតបានទេ ដល់វ័យដែលកូនមានគូស្រករហើយ ទោះបីយកភេទដូចគ្នាក៏ដោយ ក៏អត់មានបញ្ហាអីដែរ ឱ្យតែចេះស្រឡាញ់គ្នា។ បើចិត្តគេស្រឡាញ់គ្នាហើយ យើងទៅពង្រត់គេ គឺបាប។ កូនៗខ្ញុំគេមានគ្រួសារ គេចែកមុខរបរគ្នាដើម្បីផ្គត់ផ្គង់គ្នាទៅវិញទៅមក ដូច្នេះខ្ញុំអត់សូវលំបាកក្នុងអារម្មណ៍ទេ គេសប្បាយចិត្តទាំងសងខាង។ រាល់ថ្ងៃឃើញកូនមានក្តីសុខ សុភមង្គលបែបនេះ ខ្ញុំជាពុកជាម៉ែ រីករាយរំភើបរកអ្វីប្រៀបមិនបានទេ ហើយក៏មានក្តីប្រាថ្នាចង់ឱ្យកូនៗអាចចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាបាន ដើថម្បីរក្សាកិត្តិយសនៅក្នុងគ្រួសារយើងបានល្អ។»*** ~ សាន មឿន និងឃី សារ៉ែន ជាឪពុកម្តាយរបស់អ្នកស្រឡាញ់ភេទដូចគ្នា រស់នៅខេត្តឧត្តរមានជ័យ។

យើងទាំងអស់គ្នាក៏នឹងបន្តធ្វើការរួមគ្នាដើម្បីជំរុញឱ្យមានវឌ្ឍនភាព ដោយរួមបញ្ចូលការប្រារព្ធកម្មវិធីប្រចាំឆ្នាំចំនួនពីរសំខាន់ៗគឺ៖ សប្តាហ៍ ឬ ខែមោទនភាព និងទិវាអន្តរជាតិស្តីពីការបញ្ឈប់ការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរយេនឌ័រ (PRIDE Week/Month - IDAHOBIT) ក្នុងខែឧសភា និងទិវាសិទ្ធិមនុស្សអន្តរជាតិ (IHRD)

ក្នុងខែធ្នូ។ កម្មវិធីទាំងនេះបង្កនូវឱកាសសម្រាប់សមាជិកសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាមកពី២៥ខេត្ត និងរាជធានីជួបជុំគ្នាជជែកពិភាក្សា ចែករំលែកនូវស្ថានភាព និងបទពិសោធសំខាន់ៗ ជួបសន្ទនាជាមួយអាជ្ញាធរមូលដ្ឋាន ក្រសួង-ស្ថាប័នថ្នាក់ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងភាគីពាក់ព័ន្ធដទៃទៀត អំពីវឌ្ឍនភាព បញ្ហាប្រឈម និងកិច្ចសហការជាបន្ត ដើម្បីដោះស្រាយ ហើយឆ្លើយតបនឹងតម្រូវការអាទិភាពរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ឱ្យកាន់តែប្រសើរឡើងជាបន្តបន្ទាប់។ ទន្ទឹមនឹងនេះ កម្មវិធីប្រគុំតន្ត្រី ការសម្តែងសិល្បៈចម្រុះ និងការប្រកួតកីឡាផ្សេងៗក៏នឹងត្រូវបានរៀបចំឡើងផងដែរ ដើម្បីជាការអបអរសាទរនូវមោទនភាព ផ្សព្វផ្សាយការយល់ដឹង និងលើកកម្ពស់ការគាំទ្ររបស់សាធារណជនចំពោះសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជាឱ្យកាន់តែទូលំទូលាយ។ កម្មវិធីទាំងនេះបង្ហាញថា សង្គមកម្ពុជាមានការគោរពនូវតម្លៃរបស់មនុស្សភាពមេត្តា អធ្យាស្រ័យ សាមគ្គីភាព បរិយាបន្ន និងភាពសុខដុមរឹងមាំ ជាឆ្អឹងមួយដ៏រឹងមាំ។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**


- **ទុយ រស្មី** ប្រធានសម្របសម្រួលផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង
  - លេខទូរស័ព្ទ ០៩៦ ២០៩ ៥៦៤ ៨ / ០៧៧ ៤៧២ ៥៥២
  - អ៊ីមែល raksmey@rockcambodia.org
- **ផូ សុភា** បុគ្គលិកផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង
  - លេខទូរស័ព្ទ ០៧០ ៦០១ ០០៨
  - អ៊ីមែល sophea@rockcambodia.org


----